European Union
Delegation to Cambodia

UNITED
NATIONS
Cambodia

# ភាពជាដៃគូដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន៖ អនុវត្តសកម្មភាពតាមរបៀបផ្សេងនៅក្នុងបរិបទថ្មី

## សេចក្តីប្រកាសព័ត៌មាន

**រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០២១** – កាលពីថ្ងៃទី ២៨ ខែ មករា តំណាងសហភាពអឺរ៉ុប និង អង្គការសហប្រជាជាតិ បានជួបប្រជុំគ្នា នៅទីក្រុងភ្នំពេញ ដើម្បីពិភាក្សាពីរបៀបធ្វើការងារឱ្យកាន់តែមានប្រសិទ្ធភាពនៅកម្ពុជា ពន្លឿនវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាព និងនាំមកនូវលទ្ធផលកាន់តែល្អ សម្រាប់ជីវិតរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប ដើម្បីកសាងឡើងវិញឱ្យកាន់តែប្រសើរ ក្រោយការឆ្លងរាលដាលជាសកលនៃជំងឺកូវីដ-១៩។

លោកជំទាវ Carmen Moreno ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា មានប្រសាសន៍ថា “យើងចង់ធ្វើការងារឱ្យកាន់តែមានប្រសិទ្ធភាព ព្រមទាំងសម្រេចឱ្យបាននូវផលជះ និងលទ្ធផលកាន់តែប្រសើរនាពេលអនាគត។ ដើម្បីសម្រេចគោលដៅនេះ យើងចាំបាច់ត្រូវធ្វើការកែលម្អរបៀបរបបធ្វើការងាររបស់យើង ហើយនេះគឺជាគោលបំណងនៃកិច្ចពិគ្រោះយោបល់រវាងសហភាពអឺរ៉ុប និងអង្គការសហប្រជាជាតិ។” លោកជំទាវបានបន្តពន្យល់ថា ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បានបង្កើតនូវបរិបទថ្មីមួយ សម្រាប់ការអនុវត្តការងារនៅក្នុងវិស័យអភិវឌ្ឍន៍។

លោកជំទាវមានប្រសាសន៍បន្តទៀតថា “គ្រប់ប្រទេសទាំងអស់ត្រូវយកធនធានមកប្រើប្រាស់សម្រាប់ការស្តារឡើងវិញក្រោយជំងឺកូវីដ-១៩។ ប៉ុន្តែ យើងមិនអាចត្រឡប់ទៅរករបៀបធ្វើការងារបែបគំរូចាស់នោះឡើយ។ ប្រទេសនានាចាំបាច់ត្រូវចាប់ផ្តើមជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ ប៉ុន្តែវិស័យអភិវឌ្ឍន៍មានវិសាលភាពធំជាងនេះឆ្ងាយ។ ការអភិវឌ្ឍ សំដៅលើការបង្កើតឱកាសសម្រាប់មនុស្ស ធ្វើឱ្យជីវិតរបស់ពួកគេកាន់តែមានភាពសម្បូរបែប ព្រមទាំងពង្រីកការអនុវត្តសិទ្ធិរបស់ពួកគេ។ ដូច្នេះ យើងចាំបាច់ត្រូវរិះរកវិធី ដើម្បីឱ្យការអនុវត្តការងារទាំងនេះកាន់តែមានប្រសិទ្ធភាព និងស្វែងរកវិធីដើម្បីឱ្យយើងអាចសម្រេចលទ្ធផលបានកាន់តែប្រសើរ។”

លោកស្រី Pauline Tamesis ប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា បានកត់សម្គាល់ថា “ភាពជាដៃគូស៊ីជម្រៅ មានសារៈសំខាន់ ជាពិសេស នៅក្នុងកាលៈទេសៈនាពេលនេះ ដែលវិសមភាពកំពុងមានការកើនឡើង និងនៅក្នុងកាលៈទេសៈនៃការស្តារឡើងវិញពីជំងឺកូវីដ-១៩ ដែលចាំបាច់ត្រូវមានការពង្រឹង

សាមគ្គីភាព និងការប្រកាន់យកស្មារតីពហុនិយម។ សហភាពអឺរ៉ុប និងអង្គការសហប្រជាជាតិមានគុណតម្លៃរួមដូចគ្នា។ ហើយយើងប្តេជ្ញាចិត្តលើកកម្ពស់ការគោរពសិទ្ធិមនុស្ស ការអភិវឌ្ឍដោយចីរភាព និងការធានាឱ្យមានការផ្តល់ភាពអង់អាច និងការការពារមនុស្សជាតិ ព្រមទាំងភពផែនដីទាំងមូល។"

សហភាពអឺរ៉ុប និងរដ្ឋជាសមាជិករបស់សហភាពអឺរ៉ុប រួមគ្នា គឺជាដៃគូធំជាងគេទី ២ របស់កម្ពុជា បើគិតជាចំនួនថវិកាជំនួយសម្រាប់ការអភិវឌ្ឍ ដោយមានអង្គការសហប្រជាជាតិ ដើរតួនាទីជាទីភ្នាក់ងារអនុវត្តន៍ជាដំរាបមក។ គម្រោងដែលសហភាពអឺរ៉ុប និងទីភ្នាក់ងារសហប្រជាជាតិជាដៃគូកំពុងអនុវត្តនៅកម្ពុជា មានទឹកប្រាក់ជាង ១០០ លានដុល្លារ ហើយជាគម្រោងដែលមានការចូលរួមពីពលរដ្ឋកម្ពុជានៅគ្រប់ស្រទាប់វណ្ណៈក្នុងវិស័យជាច្រើន ដូចជា អប់រំ កសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ អភិបាលកិច្ច សិទ្ធិមនុស្ស សេវាគាំពារសង្គម ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍវិស័យឯកជន និងការប្រែប្រួលអាកាសធាតុ។

បើទោះជាកិច្ចពិគ្រោះយោបល់នេះផ្តោតលើផលវិបាកធ្ងន់ធ្ងរដែលបង្កឡើងដោយសារការឆ្លងរាលដាលជាសកលនៃជំងឺកូវីដ-១៩យ៉ាងណាក៏ដោយ ប្រតិភូចំនួន ៤០ នាក់ដែលបានចូលរួមនៅក្នុងកិច្ចប្រជុំនេះ បានបង្ហាញនូវក្តីសង្ឃឹម ដោយយល់ស្របគ្នាថា បរិបទថ្មីនេះផ្តល់នូវឱកាសដែលមានតែម្តងក្នុងមួយជំនាន់ ដើម្បីនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងប្រព័ន្ធ ដែលគេប្រហែលជាមិនអាចធ្វើបានឡើយ ប្រសិនបើពុំមានវិបត្តិនេះ។

លោកស្រី Pauline Tamesis មានប្រសាសន៍ថា "សូម្បីតែនៅក្នុងស្ថានភាពសោកសៅ ពោលគឺសូម្បីតែពេលដែលមានផលវិបាកធ្ងន់ធ្ងរជាច្រើនកំពុងកើតមានឡើង ដូចដែលយើងទាំងអស់គ្នាបានមើលឃើញចេញពីការឆ្លងរាលដាលជាសកលនេះក៏ដោយ យើងក៏បានមើលឃើញនូវក្តីសង្ឃឹមផងដែរ។ យើងមើលក្តីសង្ឃឹមនេះតាមរយៈគោលនយោបាយដែលនាំមកនូវការផ្លាស់ប្តូរជាវិជ្ជមាន ដែលរដ្ឋាភិបាលជាច្រើនបានដាក់ឱ្យអនុវត្ត ជាគោលនយោបាយដែលគេពុំធ្លាប់ដែលគិតដល់កន្លងមក។ ទាំងនេះគឺជាគោលនយោបាយដែលយើងមិនធ្លាប់ស្រមៃឃើញឡើយកន្លងមក ប៉ុន្តែឥឡូវនេះយើងបានមើលឃើញវា។ នេះគឺជាមូលដ្ឋានដែលជំងឺកូវីដ-១៩ ផ្តល់ឱកាសឱ្យយើងធ្វើការផ្លាស់ប្តូរ។ វិបត្តិនេះបានផ្តល់ឱ្យយើងនូវក្តីសង្ឃឹម ដើម្បីកសាងឡើងវិញឱ្យកាន់តែប្រសើរ។"

### *ព័ត៌មានទំនាក់ទំនងសម្រាប់អ្នកសារព័ត៌មាន៖*


- កញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនងនៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា៖ sreysros.keo@un.org
- លោកស្រី ពូន ប៉ុក មន្ត្រីផ្នែកសារព័ត៌មាននៃប្រតិភូសហភាពអឺរ៉ុបប្រចាំកម្ពុជា៖ pok.poun@eeas.europa.eu